បកប្រែក្រៅផ្លូវការ

# សេចក្តីថ្លែងការណ៍នៅក្នុងកិច្ចប្រជុំនៃរដ្ឋភាគីនៃអនុសញ្ញា

# ក្រុងអូតាវ៉ា

# ដោយ

# លោក កាង យ៉ុង

# ប្រធានគណៈប្រតិភូអ្នកសង្កេតការណ៍ចិន

រាជធានីភ្នំពេញថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១

លោកប្រធានជាទីគោរព

ខ្ញុំមានកិត្តិយសដោយបានចូលរួមក្នុងកិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគីនៃអនុសញ្ញាក្រុងអូតាវ៉ា។ ខ្ញុំមានសេចក្តីរីករាយដោយឃើញ ឯកឧត្តម ប្រាក់ សុខុន ដឹកនាំកិច្ចប្រជុំនេះដោយផ្ទាល់ ដែលឆ្លុះបញ្ចាំងសារៈសំខាន់ដ៏ធំរបស់រាជរដ្ឋាភិបាលកម្ពុជាផ្សារភ្ជាប់ទៅនឹងបញ្ហាគ្រាប់មីន។ ខ្ញុំមានជំនឿថា ជាមួយសមត្ថភាពនិងភាពឈ្លាសវៃដ៏លេចធ្លោរបស់ឯកឧត្តម ឯកឧត្តមនឹងពិតជាដឹកនាំកិច្ចប្រជុំរបស់យើងឲ្យសម្រេចបានលទ្ធផលជាវិជ្ជមាន។ ទន្ទឹមនឹងនេះ ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីសម្តែងអំណរគុណជូនរាជរដ្ឋាភិបាលកម្ពុជាចំពោះកិច្ចប្រឹងប្រែងដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើសម្រាប់កិច្ចប្រជុំនេះក្នុងឋានៈជាម្ចាស់ផ្ទះ។

លោកប្រធានជាទីគោរព

ចាប់តាំងពីពេលចូលជាធរមានក្នុងឆ្នាំ ១៩៩៩ អនុសញ្ញាក្រុងអូតាវ៉ាបានធ្វើការរួមវិភាគទានដ៏សំខាន់ដល់ការឆ្លើយតបទៅនឹងការបារម្ភខាងមនុស្សធម៌ ដែលបណ្តាលមកពីគ្រាប់មីនប្រឆាំងមនុស្ស (APLs)។ ជានិច្ចកាលរដ្ឋាភិបាលចិនបានផ្សារភ្ជាប់សារៈសំខាន់ដ៏ធំទៅនឹងទៅនឹងការបារម្ភខាងមនុស្សធម៌ ដែលបណ្តាលមកពីគ្រាប់មីនប្រឆាំងមនុស្ស (APLs) និង បានគាំទ្រកិច្ចប្រឹងប្រែងរបស់សហគមន៍អន្តរជាតិ ក្នុងការដោះស្រាយការបារម្ភនេះ។ ប្រទេសចិននៅមិនទាន់បានចូលក្នុងអនុសញ្ញានេះទេ ដោយសារការបារម្ភរបស់ខ្លួនអំពីភាពចាំបាច់សមហេតុផលនៃកិច្ចការពារជាតិ។ ថ្វីបើមិនមែនជារដ្ឋភាគីមួយនៃអនុសញ្ញាក្តី ក៏ប្រទេសចិនគាំទ្រគោលបំណងនិងគោលដៅនៃអនុសញ្ញានេះដែរ និង វាយតម្លៃខ្ពស់ចំពោះស្មារតីមនុស្សធម៌ដែលឆ្លុះបញ្ចាំងនៅក្នុងអនុសញ្ញានេះ។ ក្នុងបណ្តាឆ្នាំថ្មីៗនេះ ប្រទេសចិនបានចូលរួមក្នុងកិច្ចប្រជុំទាំងអស់នៃរដ្ឋភាគីនៃអនុសញ្ញា សកម្មភាពពាក់ព័ន្ធផ្សេងទៀត និង បានបោះឆ្នោតជានិច្ចគាំទ្រសេចក្តីសម្រេចស្តីពីការអនុវត្តអនុសញ្ញាក្រុងអូតាវ៉ានៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ ដែលឆ្លុះបញ្ចាំងជំហរនិងអកប្បកិរិយារបស់ចិនអំពីអនុសញ្ញានេះ។

ក្នុងឋានៈជាភាគីមួយនៃភាគីចុះកិច្ចសន្យាជាន់ខ្ពស់នៃពិធីសារវិសោធនកម្មស្តីពីមីន (ពិធីសារវិសោធនកម្មទី ២) នៃ CCW ប្រទេសចិន តែងតែបានបំពេញ យ៉ាងស្មោះត្រង់ នូវកាតព្វកិច្ចរបស់ខ្លួនក្រោមពិធីសារនេះ។ ចាប់តាំងពីទសវត្សរ៍ ១៩៩០ មក ប្រទេសចិនបានធ្វើសកម្មភាពសម្អាតមីនក្នុងទ្រង់ទ្រាយធំនៅតាមតំបន់

ព្រំដែន និង ជារួម បានលុបបំបាត់ការឈឺចាប់ដោយគ្រាប់មីននៅក្នុងបូរណភាពដែនដីរបស់យើង។ កងកម្លាំងយោធាចិនបានបំផ្លាញនិងបោះបង់ចោល APLs ចាស់និងហួសសម័យជាច្រើន ដែលមិនបំពេញតាមលក្ខខណ្ឌបច្ចេកទេសនៃពិធីសារ និង បានអភិវឌ្ឍឧបករណ៍សម្រាប់ការបំផ្លាញនិងការរុះបំបែកគ្រាប់មីនជាកិច្ចប្រឹងប្រែងដើម្បីកែលម្អបច្ចេកវិទ្យាសម្រាប់ការបំផ្លាញ។ ប្រទេសចិននឹងបន្តគោរពតាមការតាំងចិត្តរបស់ខ្លួនលើការមិននាំចេញ APLs។

លោកប្រធានជាទីគោរព

ចាប់តាំងពីឆ្នាំ ១៩៩៨ មក រដ្ឋាភិបាលចិនបានចូលរួមយ៉ាងសកម្មនៅក្នុងការផ្តល់ជំនួយអន្តរជាតិសម្រាប់បោសសម្អាតមីន។ តាមរយៈទម្រង់ផ្សេងៗ ដូចជាការផ្តល់ហិរញ្ញប្បទាន ទទួលរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេស ផ្តល់ឧបករណ៍ដោះមីន ជួយជនរងគ្រោះ ណែនាំការដោះមីនដោយផ្ទាល់ និង ការដោះមីននៅនឹងកន្លែង រដ្ឋាភិបាលចិនបានផ្តល់ជូនប្រទេសកំពុងអភិវឌ្ឍជិត ៤០ នៅអាស៊ី អាហ្វ្រិក និង អាមេរិកឡាទីននូវជំនួយដោះមីនដែលមានតម្លៃជាង ៦០ លានយាន់ រួមមានការបណ្តុះបណ្តាលអ្នកឯកទេសដោះមីនជាង ៤០០ នាក់ ដោយដឹកនាំការបោសសម្អាតផ្ទៃដីមានមីនជាង ២០.០០០ ម៉ែត្រការ៉េ។ ឆ្នាំនេះ រដ្ឋាភិបាលចិនបានរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសស្តីពីការដោះមីនមនុស្សធម៌ ជូនប្រទេសស្រីលង្កា ស៊ូដង់ និង ស៊ូដង់ខាងត្បូង និង បានបណ្តុះបណ្តាលអ្នកឯកទេសដោះមីនសរុបចំនួន ៥០ នាក់។ រដ្ឋាភិបាលចិនក៏បានផ្តល់ជូនប្រទេសឡាវ ប៉េរូ និង អេត្យូពី ផងដែរនូវជំនួយសម្រាប់ជនរងគ្រោះដោយគ្រាប់មីនក្នុងឆ្នាំនេះ។ រដ្ឋាភិបាលចិនមានឆន្ទៈបន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយប្រទេសទទួលជំនួយ និង អង្គការអន្តរជាតិពាក់ព័ន្ធ ក្នុងការផ្តល់ជំនួយមនុស្សធម៌ប្រភេទនេះ។

ប្រទេសចិនវាយតម្លៃខ្ពស់ចំពោះតួនាទីដ៏សំខាន់ដែលអង្គការអន្តរជាតិពាក់ព័ន្ធមាននៅក្នុងវិស័យមនុស្សធម៌។ ខណៈដែលបំពេញដោយស្មោះត្រង់នូវកាតព្វកិច្ចក្រោមពិធីសារវិសោធនកម្មទី២ នៃ CCW ប្រទេសចិនក៏ចូលរួមយ៉ាងសកម្មផងដែរនៅក្នុងកិច្ចសហប្រតិបត្តិការនិងការផ្លាស់ប្តូរអន្តរជាតិ នៅក្នុងវិស័យមនុស្សធម៌។ ប្រទេសចិនចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ក្រុមគាំទ្រការបោសសម្អាតមីន និង តាមដានសកម្មភាពបោសសម្អាតមីនអន្តរជាតិ។ ប្រទេសចិនរក្សាការប្រាស្រ័យទាក់ទងនិងកិច្ចសហប្រតិបត្តិការល្អ

ជាមួយ UNMAS រួមមានការមានការពិភាក្សាស៊ីជម្រៅអំពីបទដ្ឋានបោសសម្អាតមីនមនុស្សធម៌។ ឆ្នាំនេះ ប្រទេសចិនបានបញ្ជូនជំនាញការឲ្យចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលមួយ ដែលរៀបចំដោយមជ្ឈមណ្ឌលអន្តរជាតិក្រុងហ្សឺណែវសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ (GICHD) និង កំពុងពិចារណាអំពីការដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងអេឡិកត្រូនិកសម្រាប់ការបោសសម្អាតមីនមនុស្សធម៌។ ប្រទេសចិនផ្សារភ្ជាប់សារៈសំខាន់ដ៏ធំទៅនឹងតួនាទីដែលគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) មាននៅក្នុងជំនួយបោសសម្អាតមីនមនុស្សធម៌ និង រក្សាការផ្លាស់ប្តូរទៀងទាត់ជាមួយ ICRC។ ម្យ៉ាងទៀត ប្រទេសចិនរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលមានឥទ្ធិពលដ៏ធំនៅក្នុងវិស័យមនុស្សធម៌ រួមមាន ICBL ហើយការយល់គ្នាត្រូវបានលើកកម្ពស់រវាងប្រទេសចិន និង អង្គការមិនមែនរដ្ឋាភិបាលទាំងនោះ។

លោកប្រធានជាទីគោរព

ប្រទេសចិនត្រៀមខ្លួនជាស្រេចហើយដើម្បីពង្រឹងបន្ថែមទៀតនូវការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋភាគីនៃអនុសញ្ញា ទីភ្នាក់ងារអន្តរជាតិពាក់ព័ន្ធ និង អង្គការមិនមែនរដ្ឋាភិបាល សំដៅជម្រុញសកម្មភាពបោសសម្អាតមីនអន្តរជាតិ ដើម្បីរួមចំណែកដល់ការកាត់បន្ថយគ្រោះថ្នាក់ដល់ជនស៊ីវិលដែលបណ្ដាលមកពី APLs និង ដើម្បីវឌ្ឍនភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៅក្នុងតំបន់និងប្រទេសពាក់ព័ន្ធ។

សូមអរគុណ លោកប្រធាន